ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# ដើមកំណើតនៃសេចក្តីទុក្ខព្រួយរបស់មនុស្ស



និពន្ធដោយ៖ Edward Hughes

ធ្វើការពន្យល់ដោយ៖ Byron Unger; Lazarus Alastair Paterson

កែសម្រួលដោយ៖ M. Maillot; Tammy S.

បកប្រែដោយ៖ www.christian-translation.com

ផលិតដោយ៖ Bible for Children
www.M1914.org

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណ៖ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។


ព្រះជាម្ចាស់បានបង្កើតគ្រប់យ៉ាង!
ពេលទ្រង់បង្កើតមនុស្សដំបូងមកគឺលោក
អាដាម, គេបានរស់នៅក្នុងសួនអ៊ីដែន
ជាមួយប្រពន្ធរបស់គេ, អ៊ីវ។ ពួកគេរស់
នៅយ៉ាងមានសុភមង្គលក្រោមបង្គាប់
របស់ព្រះ ហើយរីករាយនឹង
វត្តមានរបស់ទ្រង់ រហូតដល់
ថ្ងៃមួយ...



សត្វពស់បានសួរទៅ
អ៊ីវថា “តើព្រះជាម្ចាស់
ហាមមិនអោយបរិភោគ
ពីគ្រប់ដើមឈើមែនទេ?”
អ៊ីវបានឆ្លើយថា “យើងអាចបរិភោគបាននូវផ្លែ
ឈើគ្រប់មុខ លើកលែងតែមួយ”។ “ប្រសិនបើ
យើងបរិភោគ ឬប៉ះផ្លែនោះ យើងនឹងស្លាប់។”
សត្វពស់បានសើចហើយ
និយាយថា “អ្នកនឹងមិន
ស្លាប់ទេ។ អ្នកនឹងក្លាយដូច
ជាព្រះ។” អ៊ីវចង់បានផ្លែពី
ដើមឈើនោះ។
នាងបាន
ស្តាប់តាមសត្វពស់
ហើយបានបរិភោគផ្លែនោះ។



បន្ទាប់ពីអ៊ីវមិនគោរពតាមបង្គាប់ព្រះហើយ នាងបាននាំអោយអាដាមបរិភោគផ្លែនោះដែរ។ អាដាមគួរតែនិយាយថា “ទេ ខ្ញុំគោរពតាមបន្ទូលរបស់ព្រះទៅអ៊ីវ តែគេមិនបាននិយាយប្រកែក
នឹងអ៊ីវឡើយ។”



ពេលដែលអាដាម
និងអ៊ីវបានប្រព្រឹត្តអំពើបាប, ពួកគេ
ចាប់ផ្ដើមមានភាពអៀនខ្មាស់។ ពួកគេបានដឹងថាពួក
គេនូវអាក្រាតនៅឡើយ ដូច្នេះហើយគេបានដេស្លឹកឈើ
ផ្ទើជាអៀម គ្របដណ្ដប់លើខ្លួនពួកគេ ហើយលាក់ខ្លួន
ក្នុងគុម្ពព្រៃពីវត្តមានរបស់ព្រះ។



ពេលល្ងាចត្រជាក់មួយ ព្រះទ្រង់បានយាងមកក្នុងសួនច្បារ។
ទ្រង់បានដឹងពីអ្វីដែលអាដាម និងអ៊ីវបានធ្វើ។
អាដាមបានបន្ទោសអ៊ីវ អ៊ីវបានបន្ទោសសត្វពស់។
ព្រះជាម្ចាស់បានមានបន្ទូលថា “សត្វពស់ត្រូវបាន
ដាក់បណ្ដាសារហើយ ហើយវានឹងវារលើពោះ
របស់វាជារៀងរហូត។ ហើយចំណែកស្ត្រីវិញ
នឹងមានការឈឺចាប់ពេលបង្កើតកូន។”
“អាដាមដោយសារអំពើបាបរបស់អែង
ដីនឹងត្រូវដាក់បណ្ដាសារ។
អែងនឹងទទួលផលពីដី
បានដោយនឿយ
ហត់បំផុត។”



ព្រះជាម្ចាស់បានបណ្ដេញអាដាម
និងអ៊ីវចេញពីសួនដ៏អស្ចារ្យ។
ដោយសារពួកគេបានប្រព្រឹត្ត
អំពើបាប ពួកគេត្រូវបាន
បំបែកចេញពីជីវិតដែលទំនុក
បម្រុងដោយព្រះ
ជាម្ចាស់!



ព្រះជាម្ចាស់បានដាក់ដាវអណ្ដាត
ភ្លើងដើម្បីការពារកុំអោយពួកគេ
ចូលមកវិញបាន។ ព្រះបានធ្វើអាវ
ពីស្បែកសត្វសម្រាប់អាដាម
និងអ៊ីវ។ តើព្រះជាម្ចាស់
បានស្បែកនោះ
ពីណាមក?

កន្លងក្រោយមក អាដាម និងអ៊ីវ បានបង្កើតជាគ្រួសារមួយ។ កូនប្រុសទីមួយរបស់ពួកគេ “កាអ៊ីន” គឺជាអ្នកថែសួនម្នាក់។ កូនប្រុសទីពីររបស់ពួកគេ, អាប៊ែល គឺជាអ្នកគង្វាលចៀម។



ថ្ងៃមួយ កាអ៊ីនបានយកបន្លែមួយចំនួនជាដង្វាយដល់ព្រះ
ជាម្ចាស់ ចំណែកអាប៊ែលវិញក៏បានយកសត្វចៀមមួយ
ចំនួនដែលល្អបំផុតរបស់គាត់ជាដង្វាយដល់ព្រះជាម្ចាស់ដែរ។
ព្រះជាម្ចាស់ពេញចិត្តនឹងដ
ង្វាយរបស់អាប៊ែល។



ព្រះជាម្ចាស់មិនពេញចិត្តនឹងដង្វាយ
របស់កាអ៊ីនទេ។ កាអ៊ីនមានចិត្តខឹង
សម្បារ។ ប៉ុន្តែព្រះជាម្ចាស់បានមាន
បន្ទូលថា “ប្រសិនបើអែងធ្វើនូវអ្វីដែល
ត្រឹមត្រូវនោះ តើនរណាទៅដែលមិន
ទទួលយកអែង?”



កំហឹងរបស់កាអ៊ីនមិនបានរលាយ
បាត់ទេ។ មួយរយៈពេលក្រោយមក
នៅទីវាលគេបានវាយប្រហារអាបែល
ហើយសម្លាប់អាបែល។



ព្រះជាម្ចាស់បានមានបន្ទូលទៅកាអ៊ីន។ “តើប្អូនប្រុសរបស់
អែង,អាប៊ែលនៅឯណា?” កាអ៊ីនបាននិយាយកុហកថា “ខ្ញុំ
មិនដឹងទេ “ខ្ញុំមិនមែនម៉ែដោះរបស់ប្អូនខ្ញុំទេ?” ព្រះជាម្ចាស់
បានដាក់ទោសកាអ៊ីន ដោយដកយក
សមត្ថភាពរបស់គេក្នុងការដាំដំនាំ
ហើយធ្វើអោយគេក្លាយជាជនអនាថា។



កាអ៊ីនបានចាកចេញពីវត្តមានរបស់ព្រះ។ គេបានរៀបការ
នឹងកូនស្រីម្នាក់របស់អាដាម និងអ៊ីវ។ ពួកគេបានបង្កើត
ជាគ្រួសារមួយ។ មិនយូរប៉ុន្មាន កូនចៅ ចៅ
ទួតរបស់កាអ៊ីនក៏មានគ្នាច្រើនពេញ
ក្នុងទីក្រុងមួយដែលពួកគេបានកសាង
ឡើង។



ទន្ទឹមគ្នានេះដែរ គ្រួសាររបស់អាដាម និង
អ៊ីវក៏ចេះតែចម្រើនច្រើនឡើងយ៉ាងឆាប់រ
ហ័ស។ នៅជំនាន់នោះ មនុស្សរស់នៅបាន
អាយុវែងជាងនៅជំនាន់ឥឡូវនេះ។



នៅពេលដែលកូនប្រុសរបស់នាងឈ្មោះ សិតបានកើតមក, អ៊ីវបាននិយាយថា “ព្រះជាម្ចាស់អោយសិតមកខ្ញុំអោយមកជំនួសអាប៊ែល។” សិតជាមនុស្សរបស់ព្រះដែលបានរស់នៅបានដល់អាយុ៩១២ឆ្នាំ ហើយមានកូនជាច្រើននាក់។



នៅក្នុងលោកនេះ ចំនួនមនុស្សកាន់តែ
ច្រើនឡើង ហើយកាន់តែអាក្រក់ឡើង
ពីមួយដំណទៅមួយដំណ។ នៅទីបំផុត
ព្រះជាម្ចាស់បានសំរេចចិត្តបំផ្លាញ
មនុស្សជាតិ ហើយ...



...នឹងគ្រប់សត្វព្រៃ និងបក្សាបក្សីទាំង
អស់។ ព្រះជាម្ចាស់សោកស្តាយណាស់
ដែលទ្រង់បង្កើតមនុស្សមក។ ប៉ុន្តែ
មនុស្សម្នាក់បានធ្វើអោយព្រះ
ជាម្ចាស់ពេញព្រះ
ហឫទ័យ...។





បុរសម្នាក់នោះឈ្មោះ ណូអា។ ណូអា
ជាកូនចៅជំនាន់ក្រោយរបស់សិត,
ណូអាជាមនុស្សត្រឹមត្រូវ និងគ្មាន
កន្លែងទាស់ឡើយ។ គេបានដើរ
ជាមួយព្រះជាម្ចាស់។

គេក៏បានបង្រៀនកូនប្រុសទាំងបីនាក់របស់គេអោ
យគោរពព្រះជាម្ចាស់ផងដែរ។ ពេលនេះព្រះជាម្ចាស់
បានមានគំរោងប្រើណូអាដោយមធ្យោបាយ
ដ៏ចម្លែក ហើយជាមធ្យោបាយ
ដ៏ពិសេសមួយ។



ដើមកំណើតនៃសេចក្តីទុក្ខព្រួយរបស់មនុស្ស

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

លោកុប្បត្តិ ៣-៦

“ការបើកសម្តែងនូវព្រះបន្ទូលទ្រង់ផ្តល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០

ចប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គប្រាប់ថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្លេះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៌! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យ៉ូហាន ៣៖១៦